**AAC Voting Translation Project**

*Language: Khmer*

**អំពី AAC៖**

AAC គឺជាស្ថាប័នអចិន្ត្រៃយ៍មួយដែលត្រូវបានខិតខំបូជាលើការតស៊ូមតិក្នុងនាមជាជនជាតិអាមេរិកអាស៊ី នៅទូទាំងរដ្ឋម៉ាសាឈូសេត។ គោលដៅរបស់គណៈកម្មការគឺ ដើម្បីទទួលស្គាល់ និង លើកឡើងនូវការចូលរួមចំណែកយ៉ាងសំខាន់របស់ជនជាតិអាមេរិកាំងអាស៊ីចំពោះសង្គម វប្បធម៌ សេដ្ឋកិច្ច និង ជីវិតនយោបាយរបស់សហគមន៍ប្រជាពលរដ្ឋ, ដើម្បីកំណត់ និង ដោះស្រាយតម្រូវការ និង បញ្ហាប្រឈមដែលកំពុងប្រជែងនឹងប្រជាជនដែលមានជាប់ដើមកំនើត ឬពូជពង្សអាស៊ី, និង ដើម្បីលើកកម្ពស់សុខុមាលភាពរបស់សហគមន៍ប្រកបដោយភាពស្វាហាប់ និង ចម្រុះ, ដោយហេតុនេះ ទើបអាចបង្កើនផលប្រយោជន៍ដល់មនុស្សទាំងអស់ដែលហៅរដ្ឋម៉ាសាឈូសេតថាជាផ្ទះ។

ដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងលទ្ធិប្រជាធិបតេយ្យរបស់យើង ជនជាតិអាមេរិកាំងអាស៊ីត្រូវតែអនុវត្តសិទ្ធិបោះឆ្នោតក្នុងតបន់ឬមូលដ្ឋាន ,ប្រចាំរដ្ឋ និងការបោះឆ្នោតថ្នាក់ជាតិផងដែរ។

**ហេតុការណ៍ពិតនៃ MA AAPI**

- ៧៨% នៃជនជាតិអាមេរិកាំងអាស៊ីនៅរដ្ឋម៉ាសាឈូសេតនិយាយភាសាផ្សេងក្រៅពីភាសារអង់-គ្លេសនៅ ផ្ទះ ហើយក្នុងចំណោមនោះមាន ៤៤% និយាយភាសាអង់គ្លេសបានតិចជាងកំរិត“ល្អណាស” ។
- ចំនួនអ្នកចេញទៅបោះឆ្នោតដែលមានចំណេះដឹងភាសាអង់គ្លេសមានកំរិតទាប (LEP) ៩% តិចជាងអ្នកចុះឈ្មោះបោះឆ្នោតមិនមែនជា (LEP) បើយោងតាមការស្ទង់មតិក្រោយការបោះ

ឆ្នោតរបស់ AAPI ឆ្នាំ ២០១២, ហើយ ៦៣% និយាយថាជំនួយភាសាអាស៊ីនៅកន្លែងបោះឆ្នោតនឹងមានប្រយោជន៍។

- ចំនួនប្រជាពលរដ្ឋអាមេរិកាំងអាស៊ីប្រមាណ ១៤,៤២៧ នាក់នៅរដ្ឋម៉ាសាឈូសេត (៣%) ខ្វះការធានារ៉ាប់រងសុខភាព។
- ចំនួនប្រជាជនអាមេរិកកាំងអាស៊ីចំនួនប្រមាណ ៥៧.៨១៣ នាក់នៅរដ្ឋម៉ាសាឈូសេត (១៤%) រស់នៅក្នុងភាពក្រីក្រ។
- ចំនួនជនជាតិដើមអាមេរិកកោះប៉ាស៊ីហ្វិក (NHPI) ប្រមាណ ៣០៦ នាក់នៅរដ្ឋម៉ាសាឈូសេត (១៤%) រស់នៅក្នុងភាពក្រីក្រ។

## កាលបរិច្ឆេទសំខាន់ៗដែលនឹងមកដល់សម្រាប់ការបោះឆ្នោតនៅ MA

សហព័ន្ធ

- ការបោះឆ្នោតទូទៅនៅរដ្ឋម៉ាសាឈូសេត៖ ថ្ងៃទី ៣ ខែវិច្ឆិកាឆ្នាំ ២០២០
- ការបោះឆ្នោតមុនកាលកំណត់៖ ថ្ងៃទី ១៧ ខែតុលាឆ្នាំ ២០២០ - ថ្ងៃទី ៣០ ខែតុលាឆ្នាំ ២០២០
- ថ្ងៃផុតកំណត់អ្នកចុះឈ្មោះបោះឆ្នោត៖ ថ្ងៃសៅរ៍ទី ២៤ ខែតុលាឆ្នាំ ២០២០ វេលាម៉ោង ៨ : ០០ ល្ងាច ED
- ថ្ងៃផុតកំណត់ដើម្បីស្នើសុំសន្លឹកឆ្នោតអ្នកអវត្តមាន៖ ថ្ងៃទី ២៨ ខែតុលាឆ្នាំ ២០២០ ម៉ោង ១២ : ០០ ល្ងាច EDT
- ថ្ងៃផុតកំណត់នៃការផ្ញើរត្រឡប់មកវិញនូវសន្លឹកឆ្នោតដែលបានបំពេញជាស្ថាពររបស់អ្នកអវត្ត-មាន៖ ថ្ងៃទី ៣ ខែវិច្ឆិការ ឆ្នាំ ២០២០ ម៉ោង ៨ : ០០ ល្ងាច EST

## វិធីបោះឆ្នោតតាមសំបុត្រ

- ដូចដែលតម្រូវតាមច្បាប់ថ្មី ការបោះឆ្នោតតាមការដាក់ពាក្យស្នើសុំតាមសំបុត្រនឹងត្រូវបានផ្ញើទៅមនុស្សគ្រប់រូបដែលបានចុះឈ្មោះបោះឆ្នោតនៅថ្ងៃទី ១ ខែ កក្កដា និងអ្នកដែលមិនបានស្នើរសុំសន្លឹកឆ្នោតអវត្តមានសម្រាប់ការបោះឆ្នោតរដ្ឋបឋម ឬ សម្រាប់គ្រប់ការបោះឆ្នោតទាំងអស់នៅឆ្នាំនេះ។ សូមផ្ញើពាក្យសុំរបស់អ្នកឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបានដូច្នេះអ្នកអាចមានពេលគ្រប់គ្រាន់ដើម្បីទទួលសន្លឹកឆ្នោតរបស់អ្នក ហើយ ផ្ញើវាត្រលប់មកវិញទាន់ពេលដែលនឹងត្រូវរាប់។
- សំបុត្រទី២ នឹងត្រូវបានផ្ញើចេញនៅខែ កញ្ញា ដល់អ្នកបោះឆ្នោតទាំងអស់ដែលមិនបានដាក់ពាក្យសុំសន្លឹកឆ្នោតបោះតាមសំបុត្រសម្រាប់ការបោះឆ្នោត ខែ វិច្ឆិកា។ ពាក្យសុំទាំងនោះត្រូវបានផ្ញើជូនជាមុនទៅកាន់មន្ត្រីបោះឆ្នោតក្នុងតំបន់ឬមូលដ្ឋានរបស់អ្នកហើយមិនចាំបាច់តម្រូវអោយមានតែមឡើយ។ ពាក្យសុំបោះឆ្នោតផ្ញើតាមសំបុត្រត្រូវតែបញ្ជូនទៅការិយាល័យបោះឆ្នោតរបស់អ្នកមិនយឺតជាង៤ថ្ងៃធ្វើការ មុនថ្ងៃបោះឆ្នោតឡើយ។ សម្រាប់សន្លឹកឆ្នោតនៃការបោះឆ្នោតប្រចាំរដ្ឋ ការដាក់ពាក្យសុំរបស់អ្នកត្រូវតែទៅដល់ការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកមិនយឺតជាងថ្ងៃទី ២៨ ខែតុលា ឡើយ។

- ប្រសិនបើអ្នកចង់បោះឆ្នោតតាមសំបុត្រ អ្នកត្រូវបានជំរុញទឹកចិត្តយ៉ាងខ្លាំងដើម្បីប្រគល់ពាក្យស្នើរសុំត្រលប់មកវិញឱ្យបានឆាប់បំផុតដើម្បីធ្វើឱ្យប្រាកដថាអ្នកនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នកទាន់ពេលវេលា ដើម្បីផ្ញើសន្លឹកឆ្នោតត្រលប់មកវិញនិងត្រូវបានរាប់ផងដែរ។

## តួនាទីមន្ត្រីបោះឆ្នោតដែលបានជ្រើសរើស និង និយមន័យ៖

**ប្រធានាធិបតី៖** ប្រធានាធិបតីគឺជាប្រមុខរដ្ឋនិងជាប្រមុខរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក និង ជាអគ្គមេ-បញ្ជាការនៃកងកំលាំងប្រដាប់អាវុធ

**អ្នកតំណាងរដ្ឋ៖** ធ្វើការណែនាំ និង បោះឆ្នោតលើវិក័យប័ត្រដែលតំណាងឱ្យផលប្រយោជន៍របស់សមាជិកម្នាក់ៗក្នុងមណ្ឌលបោះឆ្នោត របស់ពួកគេ (ប្រជាជនដែលរស់នៅក្នុងតំបន់បោះឆ្នោតរបស់ពួកគេ) ។ ពួកគេបង្កើតច្បាប់ថ្មី កែប្រែ ឬ ធ្វើបច្ចុប្បន្នភាពច្បាប់ចាស់ និង បម្រើដល់គណៈកម្មាធិការស្រាវជ្រាវនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ។ អ្នកតំណាងរដ្ឋមួយរូប មានអាណត្តបម្រើការរយៈពេលពីរឆ្នាំ។

**សមាជិកព្រឹទ្ធសភាប្រចាំរដ្ឋ៖** ត្រូវបានជ្រើសតាំងដោយអ្នកបោះឆ្នោតដើម្បីតំណាងពួកគេនៅក្នុងព្រឹទ្ធសភារដ្ឋ ដែលជាកន្លែងដែលភារកិច្ចចម្បងរបស់ពួកគេគឺកំពុងបង្កើត ជជែកវែកញែក និង បោះឆ្នោតលើនីតិកម្មច្បាប់ដែលបង្កើតច្បាប់ថ្មី ឬកែប្រែច្បាប់ដែលមានស្រាប់។ សមាជិកព្រឹទ្ធសភារដ្ឋមួយរូប តំណាងឱ្យស្រុកច្រើនជាងមួយ និងមានអាណត្តបម្រើការរយៈពេលប្រាំមួយឆ្នាំ។

**សមាជិកសភាអាមេរិក៖** អ្នកតំណាងមួយរូបៗ ត្រូវបានជ្រើសតាំងមានអាណត្តរយៈពេលពីរឆ្នាំដើម្បី

បម្រើប្រជាជននៃមណ្ឌល ឬ ស្រុកសមាជជាក់លាក់មួយ។ ក្នុងចំណោមភារកិច្ចផ្សេងទៀត តំណាងនីមួយៗត្រូវធ្វើការណែនាំលើវិក័យប័ត្រដែលត្រូវចំនាយ និង ដំណោះស្រាយនានា, ផ្តល់ជូននូវការធ្វើវិសោធនកម្ម និង បម្រើដល់គណៈកម្មាធិការ។

**សមាជិកព្រឹទ្ធសភាអាមេរិកៈ** កាតព្វកិច្ចចម្បងរបស់សភា គឺការសរសេរ ជជែកវែកញែក និងអនុម័តច្បាប់ ដែលបន្ទាប់មកត្រូវបានបញ្ជូនទៅប្រធានាធិបតីដើម្បីសុំការអនុម័ត និងចុះហត្ថលេខាចុងក្រោយ។ មុខងារសមាជផ្សេងទៀត រួមមានការស៊ើបអង្កេតសង្កត់លើបញ្ហាជាតិ និង ការត្រួតពិនិត្យស្ថាប័ននីតិប្រ-តិបត្តិ និងតុលាការ។

**ក្រុមប្រឹក្សាអភិបាល:**ត្រូវបានគេស្គាល់ផងដែរថាជាក្រុមប្រឹក្សានីតិប្រតិបត្តិ ដែលជាស្ថាប័នរដ្ឋាភិបាល ដែលផ្តល់ដំបូន្មាន និង ការយល់ព្រមក្នុងបញ្ហាជាក់លាក់មួយចំនួន ដូចជា ការតែងតាំងតុលាការ ការ-លើកលែងទោស និង ការសម្រាលទោសជាដើម។

**បណ្តាញភ្ជាប់ (Link) នៅទីនេះសម្រាប់ទម្រង់ចុះឈ្មោះអ្នកបោះឆ្នោតៈ**

ភាសារអង់គ្លេស៖https://www.sec.state.ma.us/ele/elepdf/Voter-reg-mail-in.pdf

ភាសារខ្មែរ៖ https://www.sec.state.ma.us/ele/elepdf/Voter-reg-mail-in-Khmer.pdf

# លេខទូរស័ព្ទបន្ទាន់សម្រាប់អ្នកបោះឆ្នោតជាតិអាស៊ីអាមេរិចកាំង

ប្រសិន បើ អ្នកឬអ្នកណាម្នាក់ដែលអ្នកស្គាល់ជួបការពិបាកក្នុងការចូលប្រើភាសា ឬ ត្រូវការជំនួយក្នុងការបោះឆ្នោតផ្សេងៗ (រាប់បញ្ចូលទាំងសំណួរអំពីទីតាំងបោះឆ្នោត ឬ នីតិវិធីក្នុងការបោះឆ្នោត) សូមទូរស័ព្ទមកបណ្ដាញទូរស័ព្ទបន្ទាន់សម្រាប់អ្នកបោះឆ្នោតជាតិអាស៊ីអាមេរិចតាមលេខៈ

1-888-API-VOTE (1-888-274-8683)